ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ........................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់ប្រកាសនីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារ
## ជំនាន់ទី១៨ ទី១៩ និងទី២០
**ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣ នៅសាលសន្និសីទចតុម្មុខ**

សូមគោរព :

- **លោក Faisal Ahmed តំណាងអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ប្រចាំកម្ពុជា**
- **លោក Arnaud de Villepoix ជំនាញការទូទៅរបស់ IMF ប្រចាំនៅធនាគារជាតិនៃកម្ពុជា**
- **លោក Ye-Hong Ahn ជំនាញការធនាគារកណ្ដាលកូរ៉េប្រចាំនៅធនាគារជាតិនៃកម្ពុជា**
- **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងក្មួយៗនិស្សិតទាំងអស់ ជាទីមេត្រី !**

ថ្ងៃនេះ ខ្ញុំមានក្ដីសោមនស្សរីករាយជាអតិបរមា ដែលបានចូលរួមជាមួយ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់ប្រកាសនីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារ ជូនដល់និស្សិតជ័យលាភីជំនាន់ទី១៨ ទី១៩ និងទី២០ សរុបចំនួន ៥០៥នាក់ ដែលបានបញ្ចប់ការសិក្សាដោយជោគជ័យពីមណ្ឌលសិក្សាបច្ចេកទេសធនាគារ នាពេលនេះ ។ ខ្ញុំសង្កេតឃើញថា ក្មួយៗនិស្សិតជ័យលាភីទាំងអស់មានទឹកមុខញញឹមញញែម ស្រស់ថ្លា និងសប្បាយរីករាយយ៉ាងខ្លាំងប្រកបដោយក្ដីសង្ឃឹមជឿជាក់ និងមានមោទនភាពទៅអនាគត ។ ខ្ញុំសូមចូលរួមអបអរសាទរ ចំពោះលទ្ធផលដ៏ល្អប្រសើរនេះជាមួយឪពុកម្ដាយ និងលោកគ្រូអ្នកគ្រូរបស់ក្មួយៗផងដែរ ។

ជ័យលាភីដែលក្មួយៗទទួលបាននាពេលនេះ បានបង្ហាញពីលទ្ធផលនៃការខិតខំប្រឹងប្រែងរៀនសូត្ររបស់ក្មួយៗផង ការតបស្នងគុណរបស់ក្មួយៗចំពោះឪពុកម្ដាយ និងលោកគ្រូអ្នកគ្រូផង និងជាធនធានថ្មីរបស់យើងសម្រាប់រួមចំណែកការពារ កសាង និងអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែរីកចម្រើនថែមទៀត ។ លទ្ធផលនេះ គឺជាមោទនភាពដ៏ធំធេងរបស់ក្មួយៗនិងឪពុកម្ដាយ របស់លោកគ្រូអ្នកគ្រូនិងសាលា និងជាពិសេសសម្រាប់សង្គមជាតិទាំងមូល ដែលទទួលបានធនធានមនុស្សបន្ថែមដែលមានការបណ្ដុះបណ្ដាលសមត្ថភាព និងជំនាញថ្មីៗ ។


ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណដល់ លោក លោកស្រី លោកគ្រូអ្នកគ្រូ ដែលបានចែករំលែកចំណេះដឹងនិងបទពិសោធន៍ជូនដល់ក្មួយៗ ។ ខ្ញុំសូមថ្លែងការកោតសរសើរយ៉ាងខ្លាំង និងវាយតម្លៃយ៉ាងខ្ពស់ចំពោះលទ្ធផលនៃការខិតខំប្រឹងប្រែងសិក្សារបស់ក្មួយៗ ក្នុងរយៈពេល ២ឆ្នាំកន្លងមក លើមុខជំនាញឯកទេសធនាគារនិងហិរញ្ញវត្ថុប្រកបដោយជោគជ័យ ។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងក្មួយៗនិស្សិតទាំងអស់ ជាទីមេត្រី !**

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍នៅក្នុងឱកាសបើកបវេសនកាលឆ្នាំ ២០១២-២០១៣ នេះថា **"ការអប់រំល្អ គឺជាកូនសោរសម្រាប់ដោះស្រាយនូវរាល់បញ្ហាសង្គម-សេដ្ឋកិច្ច ហើយ ប្រជាពលរដ្ឋមានការអប់រំល្អ ទើបប្រទេសជាតិមានការអភិវឌ្ឍ"** ។ ប្រសាសន៍ដ៏ថ្លៃថ្លានេះមានន័យថា ការសិក្សារៀនសូត្រ គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ជីវិតមនុស្សម្នាក់ៗ ហើយជាការងារមួយគ្មានទីបញ្ចប់ សម្រាប់ធានាដល់ការអភិវឌ្ឍលើគ្រប់វិស័យ ពីព្រោះថា កិច្ចការនេះបានផលិតធនធានមនុស្ស ប្រកបដោយគុណភាព និងសមត្ថភាពខ្ពស់សម្រាប់រួមចំណែកអភិវឌ្ឍសង្គម និងប្រទេសជាតិ ។

ធនធានមនុស្សមានសារៈសំខាន់ណាស់ ។ ធនធានមនុស្សក្រៅពីកាយសម្បទាជារូបវន្ត គឺផ្ដោតជាសំខាន់ទៅលើទ្រព្យបញ្ញារបស់ពលករជំនាញ អ្នកគ្រប់គ្រង អ្នករៀបចំយុទ្ធសាស្ត្រ អ្នកសម្របសម្រួល និងអ្នកដឹកនាំនយោបាយរបស់ស្ថាប័នឬប្រទេសជាតិមួយ ដែលជាអ្នកដំណើរការស្ថាប័នឬប្រទេសជាតិនោះ ឱ្យប្រព្រឹត្តទៅដោយរលូន មានប្រសិទ្ធភាព និងចំគោលដៅ ឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព ។ ការអភិវឌ្ឍធនធានមនុស្ស គឺជាគន្លឹះក្នុងការកសាងនិងអភិវឌ្ឍប្រទេសជាតិ ។

បច្ចុប្បន្ន រដ្ឋត្រូវផ្ដោតការយកចិត្តទុកដាក់ក្នុងការវិនិយោគលើការអភិវឌ្ឍធនធានមនុស្ស បំណងធ្វើឱ្យប្រជាពលរដ្ឋមានចំណេះដឹង និងមានជំនាញប្រកបទៅដោយគុណភាពខ្ពស់ និងមានប្រសិទ្ធភាព មិនមែនគ្រាន់តែជាការខិតខំប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាអាជីព ក្នុងពេលបច្ចុប្បន្នរយៈពេលខ្លីប៉ុណ្ណោះទេ ប៉ុន្តែ គឺជាចក្ខុវិស័យវែងឆ្ងាយសម្រាប់អភិវឌ្ឍ និងជាការវិនិយោគទៅលើការពង្រឹងសមត្ថភាពប្រជែងឈ្នះរបស់ជាតិនៅពេលអនាគត ដែលជាយុគសម័យសេរីភាវូបនីយកម្ម និងការប្រកួតប្រជែងខាងសេដ្ឋកិច្ច ផ្អែកលើចំណេះដឹង និងព័ត៌មានវិទ្យា ។

ការអភិវឌ្ឍធនធានមនុស្ស គឺត្រូវបណ្ដុះបណ្ដាលផ្នែកកម្លាំងកាយ និងកម្លាំងប្រាជ្ញា-ស្មារតី ។ ការអភិវឌ្ឍកម្លាំងប្រាជ្ញា-ស្មារតី គឺបណ្ដុះបណ្ដាលចំណេះដឹងផ្នែកទ្រឹស្ដីនិងការអនុវត្ត (IQ) ព្រមទាំងសីលធម៌ និងចរិយាធម៌ (EQ) ។ ការបណ្ដុះបណ្ដាលធនធានមនុស្សប្រកបដោយប្រសិទ្ធភាព គឺអាស្រ័យលើការគ្រប់គ្រង និងការចាត់ចែងធនធានមនុស្សបានល្អ ស្របតាម

ជំនាញនិងសមត្ថភាព ។ យើងមានការគ្រប់គ្រងធនធានមនុស្សស្របតាមតម្រូវការ និងប្រកបដោយប្រសិទ្ធភាព ហើយគួបផ្សំនឹងស្ថិរភាពនយោបាយនិងធនធានធម្មជាតិ នឹងនាំឱ្យប្រទេសជាតិមានការអភិវឌ្ឍជានិច្ចនិរន្តរ៍ ។

នៅក្នុងសតវត្សរ៍ទី២០ ការអភិវឌ្ឍសេដ្ឋកិច្ចត្រូវផ្អែកលើមូលដ្ឋាននៃកត្តាសំខាន់ៗបី គឺធនធានដីធ្លី កំលាំងពលកម្ម និងមូលធន ។ ក្នុងសតវត្សរ៍ទី២១ ការអភិវឌ្ឍសេដ្ឋកិច្ចនិងប្រទេសជាតិ គឺផ្អែកលើមូលដ្ឋានទ្រព្យបញ្ញា ដោយការប្រើគំនិតបង្កើតថ្មី (Creativity) គំនិតច្នៃប្រឌិត (Innovation) និងចំណេះដឹងផ្នែកជំនាញឯកទេសកម្ម (Technical Skills) នានាជាជាងការប្រើប្រាស់កត្តាផលិតកម្មប្រពៃណីឯទៀត ដូចជា ធនធានដីធ្លី និងកំលាំងពលកម្មសម្រាប់គាំទ្រការអភិវឌ្ឍ ។

ថ្មីៗនេះ តាមរយៈ "នយោបាយចាស់-សកម្មភាពថ្មី លើវិស័យដីធ្លី" របស់រាជរដ្ឋាភិបាលសម្តេចតេជោនាយករដ្ឋមន្ត្រី បានផ្តល់ឱកាសឱ្យយុវជនចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលដើម្បីវាស់វែងដីធ្លី និងផ្តល់ប័ណ្ណកម្មសិទ្ធជូនប្រជាជនទូទាំងប្រទេស ។ ការងារនេះមិនត្រឹមតែបានបង្រៀនយុវជនយើង អំពីអត្ថន័យជាប្រវត្តិសាស្ត្រ និងសារៈសំខាន់នៃការចែកប័ណ្ណកម្មសិទ្ធដីធ្លីប៉ុណ្ណោះទេ ថែមទាំងបានបណ្តុះស្មារតីយុវជនយើងឱ្យចេះតស៊ូអត់ធ្មត់ ទទួលខុសត្រូវគោរពវិន័យការងារ ស្រលាញ់ជាតិនិងប្រជាជន និងមានឆន្ទៈស្នេហាជាតិមាតុភូមិថែមទៀត ។

ក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលបានកំណត់ថា "ការអប់រំសម្រាប់ទាំងអស់គ្នា-ទាំងអស់គ្នាដើម្បីការអប់រំ" ។ ពោលគឺ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ក្នុងការកសាង និងអភិវឌ្ឍធនធានមនុស្ស ដើម្បីលើកកម្ពស់គុណភាពនៃការអប់រំ និងបង្កើនសមត្ថភាពការងាររបស់យុវជនកម្ពុជាលើគ្រប់វិស័យ ក្នុងគោលបំណងជួយពន្លឿនសមាហរណកម្មកម្ពុជាឱ្យស្មើសិទ្ធិនិងស្មើភាពក្នុងគ្រប់កិច្ចការតំបន់ និងពិភពលោក និងសម្រេចបានយ៉ាងពិតប្រាកដនូវកំណើនសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើចំណេះដឹង និងធានានូវឧត្តមភាពដណ្តើមឈ្នះរបស់ប្រទេសជាតិក្នុងតំបន់ផងដែរ ។ យុវជន ជាកម្លាំងបន្តវេននិងជាប្រភពមិនចេះរីងស្ងួតក្នុងបុព្វហេតុការពារ កសាង និងអភិវឌ្ឍប្រទេសជាតិប្រកបដោយថាមពលនិងមានប្រសិទ្ធភាព ។

ក្នុងស្មារតីនេះហើយ ដែលយើងត្រូវប្រើកម្លាំងសរុបរួមគ្នាបន្តគាំទ្រលើកកម្ពស់វិស័យអប់រំជាតិរបស់យើង ដោយមិនត្រូវទុកឱ្យកូនចៅយើងណាម្នាក់ស្ថិតនៅក្រៅសេវាអប់រំ និងត្រូវបង្កើនសក្តានុពលឱ្យកូនចៅរបស់យើងនៅជំនាន់ក្រោយជាមនុស្សដែលមានសមត្ថភាពនិងជំនាញគ្រប់គ្នានៅពេលអនាគត ។ ចំណុចទាំងអស់នេះ យើងត្រូវយកចិត្តទុកដាក់ទាំងអស់គ្នា ដើម្បីធ្វើជាត្រីវិស័យតម្រង់ទិសឆ្ពោះទៅរកការកែទម្រង់សំដៅបន្តលើកកម្ពស់គុណភាព

និងប្រសិទ្ធភាពនៃការអប់រំបណ្តុះបណ្តាលធនធានមនុស្ស ក្នុងបរិការណ៍នៃសង្គមពុទ្ធិ និងសំដៅត្រៀមលក្ខណៈឱ្យបានល្អក្នុងការធ្វើសមាហរណកម្ម ជាមួយបណ្តាប្រទេសសមាជិកអាស៊ាន ដែលអាចធ្វើឱ្យយើងធ្វើដំណើរទៅមុខជាមួយគ្នាស្របតាមស្មារតីនៃគោលដៅរួមរបស់យើង គឺ " សហគមន៍តែមួយ-វាសនាតែមួយ " នាឆ្នាំ ២០១៥ ខាងមុខនេះ ។

កន្លងមក ធនាគារជាតិនៃកម្ពុជាបានខិតខំបណ្តុះបណ្តាលមន្ត្រីរបស់ខ្លួនច្រើនណាស់លើគ្រប់រូបភាពជាប់ជាប្រចាំទាំងរយៈពេលខ្លីនិងវែង ទាំងក្នុងនិងក្រៅប្រទេស ដើម្បីពង្រឹងប្រតិបត្តិការធនាគារ និងអភិវឌ្ឍប្រព័ន្ធធនាគារឱ្យប្រព្រឹត្តទៅដោយសុវត្ថិភាព និងមានប្រសិទ្ធភាព ។ ធនធានមនុស្សដែលយើងបណ្តុះបណ្តាលបាន មិនគ្រប់គ្រាន់នឹងតម្រូវការទីផ្សារការងារទេ ក្នុងខណៈដែលប្រទេសជាតិកំពុងអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ ជាពិសេសវិស័យធនាគារមានការអភិវឌ្ឍរីកចម្រើនយ៉ាងខ្លាំង ហើយវិស័យនេះបានស្រូបយកសមាមាត្រនៃកម្លាំងពលកម្មច្រើនជាងគេ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។

ជាក់ស្តែង មានមន្ត្រីធនាគារជាតិនៃកម្ពុជាខ្លះ បានលាឈប់ទៅបម្រើការងារនៅវិស័យឯកជន ហើយក៏មានបុគ្គលិកជំនាញនៃគ្រឹះស្ថានធនាគារខ្លះ ក៏បានប្តូរការងារពីធនាគារ១ទៅធនាគារ១ទៀត ប៉ុន្តែភាគច្រើន គឺនៅធ្វើការក្នុងប្រព័ន្ធធនាគារដដែល ។ ជារួម ការផ្លាស់ប្តូរការងារពីកន្លែង១ទៅកន្លែង១ នេះបើយើងគិតជាមីក្រូ គឺអាចប៉ះពាល់ដល់ដំណើរការនិងប្រតិបត្តិការនៃគ្រឹះស្ថានធនាគារនោះមែន ប៉ុន្តែបើយើងគិតជាម៉ាក្រូវិញ គឺជាសញ្ញាណល្អក្នុងការទៅជួយរួមចំណែកពង្រឹងនិងអភិវឌ្ឍប្រព័ន្ធធនាគារទាំមូល ឱ្យប្រព្រឹត្តទៅដោយសុវត្ថិភាព និងមានប្រសិទ្ធភាព ។ គោលដៅរយៈពេលវែងរបស់យើងនៅពេលអនាគត គឺបន្តបណ្តុះបណ្តាលធនធានមនុស្សលើផ្នែកជំនាញឯកទេស ស្របតាមតម្រូវការទីផ្សារការងារទាំងក្នុងប្រទេស និងតំបន់ ។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងក្មួយៗនិស្សិតទាំងអស់ ជាទីមេត្រី !**

ឆ្លៀតក្នុងឱកាសដែលក្មួយៗកំពុងមានសេចក្តីសប្បាយរីករាយសាទរ ចំពោះលទ្ធផលពេលនេះ និងដើម្បីឱ្យក្មួយៗសម្រេចបានជោគជ័យនៅក្នុងជីវិតនិងការងារបន្ថែមទៀត ខ្ញុំស្នើសុំឱ្យក្មួយៗត្រូវខិតខំព្យាយាមរៀនសូត្របន្ថែមលើផ្នែកជំនាញ និងបង្កើន ៖

១/- ចំណេះដឹងផ្នែកភាសាបរទេស ព្រោះភាសាបរទេស គឺជាស្ពានសម្រាប់ចម្លងចំណេះដឹងនិងការងារ ខណៈពេលដែលប្រទេសកម្ពុជាធ្វើសមាហរណកម្មសេដ្ឋកិច្ចចូលទៅក្នុងតំបន់និងពិភពលោក ។

២/- ចំណេះដឹងផ្នែកព័ត៌មានវិទ្យា នឹងជួយសម្រួលយ៉ាងច្រើនដល់ការប្រើប្រាស់នូវមូលធនបញ្ញា សម្រាប់ការងារប្រចាំថ្ងៃ ។ និយាយឱ្យខ្លីទៅ ដោយសារតែបច្ចេកវិទ្យាទំនើប

ទើបមូលធនបញ្ញាបានរីកធំធាត់យ៉ាងឆាប់រហ័ស និងសេដ្ឋកិច្ចមានការអភិវឌ្ឍ ។ បច្ចុប្បន្ននេះ ជំនាញកុំព្យូទ័រ គឺជាមធ្យោបាយយ៉ាងសំខាន់សម្រាប់ការប្រាស្រ័យទាក់ទង និងធ្វើការគ្រប់សកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគនៅក្នុងប្រទេសនិងអន្តរជាតិ ។

៣/- ការគោរពវិន័យការងារ និងស្មារតីអភិវឌ្ឍខ្លួនឯង គឺជាកត្តាផ្ទៃក្នុងយ៉ាងសំខាន់របស់ក្មួយៗផ្ទាល់ ។ ភាពជោគជ័យនៃជីវិតការងាររបស់យើង បន្ទាប់ពីមានសញ្ញាបត្រ គឺត្រូវខិតខំតស៊ូធ្វើការងារដោយអត់ធ្មត់ មានភាពស្មោះត្រង់ មានគុណធម៌ និងសាមគ្គីគ្នាល្អ មានស្មារតីទទួលខុសត្រូវខ្ពស់ និងគោរពវិន័យការងារ ទើបអនាគតរបស់ក្មួយៗបានទទួលជោគជ័យ ទាំងក្នុងការងារនិងជីវិតផ្ទាល់ខ្លួនផងដែរ ។

សូមក្មួយៗបន្តការសិក្សាស្រាវជ្រាវ ហើយត្រូវចាត់ទុកថា ការរៀនសូត្រ គឺជាដំណើរការមួយដែលមិនចេះចប់ ដើម្បីដុសខាត់ចំណេះដឹងនិងចំណេះធ្វើរបស់ខ្លួនម្នាក់ៗឱ្យកាន់តែប្រសើរថែមទៀត ទើបជាទុន និងជាយាននាំក្មួយៗសម្រេចបានស្នាដៃការងារនិងទទួលបានជោគជ័យក្នុងជីវិត និងការងារនៅពេលអនាគត។

មុននឹងបញ្ចប់ និងជាថ្មីម្តងទៀត ខ្ញុំសូមអបអរសាទរនិងជូនពរចំពោះក្មួយៗនិស្សិតទាំងអស់ សូមជួបតែសំណាងល្អ និងមានអនាគតរុងរឿង ។ បើសិនជាក្មួយៗណា មានការងារធ្វើរួចហើយ សូមឱ្យកាន់តែចម្រុងចម្រើនថែមទៀត ហើយក្មួយៗណាដែលនៅបន្តការសិក្សា សូមឱ្យទទួលបានជោគជ័យនិងមានអនាគតល្អថែមទៀត ។

ខ្ញុំសូមជូនពរចំពោះឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញាទាំងអស់ សូមមានសុខភាពល្អ កម្លាំងមាំមួន ប្រាជ្ញាវាងវៃ និងទទួលបានជ័យជម្នះគ្រប់ភារកិច្ច និងសូមជួបប្រទះតែពុទ្ធពរទាំង ៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ!**